# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតចំហ

## សូមគោរពជូន សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**សម្ដេចបវរធិបតី នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

យើងខ្ញុំជាតំណាងសមាគមសារព័ត៌មាន អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ មានក្ដីព្រួយបារម្ភយ៉ាងខ្លាំងចំពោះសេចក្ដីសម្រេចនាពេលថ្មីៗនេះ របស់តុលាការទៅលើអ្នកសារព័ត៌មានពីរនាក់ គឺលោក ផន សុភាព និងលោក ភាព ភារ៉ា ដែលត្រូវបានផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារម្នាក់រយៈពេល១៤ឆ្នាំ ។

អ្នកសារព័ត៌មានទាំងពីររូបនេះត្រូវបានសាលាដំបូងខេត្តសៀមរាប ផ្ដន្ទាទោសកាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ឱ្យជាប់ពន្ធនាគារ ១៤ឆ្នាំ ពីបទ «ផ្ដល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ ដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ» ។ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៦ សាលាឧទ្ធរណ៍នៅខេត្តបាត់ដំបង បានតម្កល់សាលក្រមសាលាដំបូងខេត្តសៀមរាប ហើយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ តុលាការកំពូលក៏បានសម្រេចតម្កល់សាលដីកាទុកជាបានការដដែល ។

នៅក្នុងអំឡុងពេលសវនាការនៅសាលាឧទ្ធរណ៍នៅខេត្តបាត់ដំបងកាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦ អ្នកសារព័ត៌មានទាំងពីរបានឆ្លើយបំភ្លឺថា នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ ពួកគេបានធ្វើដំណើរជាមួយក្រុមការងារដែលស្គាល់ថាក្រុម [ជំទាវម៉ែ] ទៅកាន់តំបន់ព្រំដែនដើម្បីនាំយកអំណោយមនុស្សធម៌ ចែកជូនកងទ័ពដែលឈរជើងនៅប្រាសាទតាក្របី ក្នុងខេត្តឧត្ដរមានជ័យ ។ នៅពេលនោះពួកគេបានប្រាប់តុលាការថា ពួកគេបានដើរបែកចេញពីក្រុមការងារ និងបានឡើងទៅប្រាសាទ ព្រោះចង់រាយការណ៍អំពីស្ថានភាពជាក់ស្ដែងនៅទីនោះ ។

ទាំងលោក ផន សុភាព និងលោក ភាព ភារ៉ា បានប្រាប់តុលាការថាមុននឹងថតរូប ពួកគេបានសុំការអនុញ្ញាតពីកងទ័ពដែលឈរជើងនៅទីនោះ និងបានបង្ហាញបណ្ណសារព័ត៌មានចេញដោយក្រសួងព័ត៌មានដល់ទាហានផងដែរ ។

ក្រោយមកពួកគេបានបង្ហោះរូបភាពដែលមានជាប់គ្រាប់មីននៅផ្ទៃខាងក្រោយនៅលើបណ្តាញសង្គមដែលរូបភាពនេះត្រូវបានប្រព័ន្ធផ្សព្វផ្សាយថៃ យកទៅចុះផ្សាយយ៉ាងទូលំទូលាយ ។

ទោះជាយ៉ាងណាក៏ដោយ អ្នកសារព័ត៌មានទាំងពីរបានអះអាងប្រាប់តុលាការថា ពួកគេមិនមានចេតនាផ្តល់ព័ត៌មានដល់ប្រទេសថៃឡើយ ។ ក្នុងសវនាការនៅតុលាការកំពូលកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៦ អ្នកសារព័ត៌មានទាំងពីរបានបន្តអះអាងថាពួកគេ គ្មានចេតនាផ្តល់ព័ត៌មានឱ្យប្រទេសឡើយ និងបានស្នើសុំឱ្យតុលាការទម្លាក់ចោលបទចោទប្រកាន់នេះ ។

នេះជាការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរបំផុតចំពោះអ្នកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា និងបង្កឱ្យមានក្តីកង្វល់យ៉ាងខ្លាំងអំពីសេរីភាពនៃការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងការប្រើប្រាស់ច្បាប់ស្តីពីសន្តិសុខជាតិមកលើអ្នកសារព័ត៌មាន ។

ក្នុងនាមជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) កម្ពុជាមានកាតព្វកិច្ចគោរព និងការពារសិទ្ធិសេរីភាពនៃការបញ្ចេញមតិ សិទ្ធិទទួលបានព័ត៌មាន សិទ្ធិសេរីភាពបុគ្គល និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ មាត្រា១៩ នៃ ICCPR ធានានូវសិទ្ធិក្នុងការស្វែងរក ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតគ្រប់ប្រភេទ ។

ករណីនេះក៏បានធ្វើឱ្យប៉ះពាល់ដល់ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការអនុវត្តអនុសាសន៍ដែលខ្លួនបានទទួលយកក្នុងអំឡុងពេលនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់(UPR)ជាពិសេសបញ្ហាដែលពាក់ព័ន្ធនឹងសេរីភាពសារព័ត៌មាន និងសេរីភាពបញ្ចេញមតិ ។ ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់សារព័ត៌មានសេរី និងឯករាជ្យ មានសារៈសំខាន់ណាស់ជាពិសេសសម្រាប់ការកសាងទំនុកចិត្ត និងភាពជឿជាក់លើឆាកអន្តរជាតិ ។

ទោះបីជាសន្តិសុខជាតិ គឺជាកង្វល់ដ៏ត្រឹមត្រូវសម្រាប់គ្រប់រដ្ឋទាំងអស់ក៏ដោយ ការដាក់កម្រិតលើសេរីភាពបញ្ចេញមតិ និងសកម្មភាពសារព័ត៌មានគួរតែមានភាពចាំបាច់ សមាមាត្រ និងស្របទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជាទាំងក្នុងរដ្ឋធម្មនុញ្ញ និងអន្តរជាតិ ។

មាត្រា២៧ នៃរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាចែងថាព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស ។ មានតែនាយករដ្ឋមន្ត្រីម្នាក់ប៉ុណ្ណោះដែលមានបុព្វសិទ្ធិស្នើព្រះមហាក្សត្រលើកលែងទោសដោយយោងតាមមាត្រា៧៧នៃច្បាប់ស្តីពី ពន្ធនាគារ ។

យើងខ្ញុំទាំងអស់គ្នាសូមស្នើសម្តេចបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាមេត្តាស្នើសុំព្រះមហាក្សត្រលើកលែងទោសដល់អ្នកសារព័ត៌មានទាំងពីររូប គឺលោក ផន សុភាព និងលោក ភាព ភា៉ ឱ្យមានសេរីភាពបានជួបជុំក្រុមគ្រួសារសាច់ញាតិ និងកូនតូចៗជាទីស្រឡាញ់របស់ពួកគាត់វិញ និងអាចឱ្យពួកគាត់ទាំងពីរបន្តការងារជាអ្នកសារព័ត៌មានបន្តទៀត ។

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងតាមរយៈ**

ណុប វី  នាយកប្រតិបត្តិ សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
+៨៥៥  ១២ ៥១៩ ២៦១

**លិខិតចំហនេះគាំទ្រដោយ៖**

១. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
២. អង្គការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ (CMPO)
៣. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ស៊ីស៊ីអាយអឹម)
៤. អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)
៥. មជ្ឈមណ្ឌលកម្ពុជាសិទ្ធិមនុស្សកម្ពុជា (CCHR)
៦. សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ)
៧. គណៈកម្មាធិការដើម្បីការពារអ្នកសារព័ត៌មាន (CPJ)
៨. អង្គការមជ្ឈមណ្ឌលធុរកិច្ច និងច្បាប់ (BHRE Center)
៩. អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ (PED)
១០. អង្គការមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
១១. សមាគមអ្នកសារព័ត៌មានទីម័រខាងកើត (AJTL)
១២. សហព័ន្ធសហជីពឯករាជ្យ (អ៊ីនទូហ្វី)
១៣. ក្រុមពង្រឹងសិទ្ធិអំណាចយុវជនដើម្បីសមធម៌សង្គម(EYES)
១៤. សមាគមបណ្តាញយុវជនកម្ពុជា (CYN)
១៥. ក្លឹបអ្នកសារព័ត៌មានបរទេសប្រចាំនៅកម្ពុជា (OPCC)
១៦. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)